ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការក្រុងព្រះសីហនុ
សាលក្រម
លេខ ៩៦ ចុះថ្ងៃទី ១៥
ខែ វិច្ឆិកា ឆ្នាំ ២០០៤
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៨៣ ចុះថ្ងៃទី ១៥ ខែ
ឧសភា ឆ្នាំ ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក **គៀង សុន្ទរោ** ជាក្រឡាបញ្ជីសវនាការ

**មេធាវី**

លោក [redacted] មេធាវីការពារជនជាប់ចោទឈ្មោះ **ស ណា**

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៣ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទ :

-ឈ្មោះ **ស ណា** ភេទស្រី អាយុ ៥៣ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មានទីលំនៅកំណើតភូមិព្រែកប្រសប់ ខេត្តក្រចេះ ទីលំនៅមុនពេលចាប់ខ្លួន ភូមិព្រែកប្រសប់ ឃុំស្រុកព្រែកប្រសប់ ខេត្តក្រចេះ មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ **ស ៩** (រ) ម្តាយឈ្មោះ **៩ ត** (រ) ប្តីឈ្មោះ **តន** លែងលះគ្នាមានកូន ០២នាក់ ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៤ ។ **ជាប់ចោទ : ពីបទ** ឆបោក ប្រព្រឹត្តនៅភូមិ ៥ សង្កាត់ ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៩-១០ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **អ ស** ភេទស្រី ជាតិខ្មែរ មានទីលំនៅភូមិ ៥ សង្កាត់ ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :**

-កាលពីថ្ងៃទី ០៩:១០ ខែ ឧសភា ឆ្នាំ ២០០៤ ឈ្មោះ **ស ណា** ភេទស្រី អាយុ ២៤ឆ្នាំ បានប្រើល្បិចធ្វើជាគ្រូទាយ និង ចូលរូបដើម្បីបោកបញ្ឆោតអ្នកស្រី **អ ស** ថា

សាលក្រមនេះចូលជាស្ថាពរតាំងពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥
ក្រុងព្រះសីហនុ,ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥
ក្រឡាបញ្ជី
[redacted]

មានកំណប់មាសចំនួន ៧០០គីឡូក្រាមកប់នៅខេត្តក្រចេះ ហើយអ្នកមានវាសនាទើបអាចយកបាន ។ ដោយមានការជឿជាក់លើគ្រូទាយ និង មានបំណងចង់បានកំណប់មាសនោះផង ក៏សំរេចចិត្តប្រគល់ប្រាក់ចំនួន ២២០.០០០រៀល "ម្ភៃពីរម៉ឺនរៀល" ទៅឱ្យគ្រូទាយទិញទៀនធូបរៀបចំពិធី ទើបយកកំណប់បាន និង នៅពេលទទួលបានកំណប់ដែលសុទ្ធតែគ្រឿងអលង្ការក្លែងក្លាយចំនួនពីរលើក គឺនៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៤ ទទួលបានមួយកញ្ចប់ បានប្រគល់ប្រាក់ឱ្យឈ្មោះ ស ណ ចំនួន ៣៥០ដុល្លា និង នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៤ ទទួលបានមួយកញ្ចប់ទៀត និង បានប្រគល់ប្រាក់ ១៥០ដុល្លាបន្ថែមទៀត សរុបទាំងអស់ឈ្មោះ ស ណ បានទទួលប្រាក់ពីអ្នកស្រី អ ស ចំនួន ២២០.០០០រៀល និង ៥០០ដុល្លា ។ លុះដល់ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៤ ទើបដឹងថា កំណប់ទាំងអស់សុទ្ធតែគ្រឿងអលង្ការក្លែងក្លាយ ទើបប្តឹងទៅសមត្ថកិច្ចចាប់ខ្លួនឈ្មោះ ស ណ បាននៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៤ បញ្ជូនមកតុលាការឃុំខ្លួនរហូតដល់សព្វថ្ងៃ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ ស ណ បានឆ្លើយថា នាងខ្ញុំមានផ្ទះនៅខេត្តក្រចេះ ក្រោយមកនាងខ្ញុំក៏ធ្វើដំណើរមកក្រុងព្រះសីហនុ ដើម្បីរកការងារធ្វើ តែរកការងារពុំបាន ហើយនាងខ្ញុំស្នាក់នៅផ្ទះគេម្នាក់នៅជិតបេនឡាន តែនាងខ្ញុំពុំធ្លាប់ស្គាល់ទេ ដោយនាងខ្ញុំមានសុខភាពខ្សោយពេក ខ្ញុំក៏សំរេចចិត្តទៅស្រុកវិញ ពេលរៀបឡើងឡានក៏មានក្មេងស្រីម្នាក់បានមកហៅខ្ញុំឱ្យទៅផ្ទះគេម្នាក់ទៀត ពេលនោះខ្ញុំក៏ជិះម៉ូតូទៅជាមួយ ពេលទៅដល់ផ្ទះនោះខ្ញុំក៏ហូបបាយជាមួយម្ចាស់ផ្ទះ ហើយក៏សំរាកនៅផ្ទះនោះមួយយប់ លុះស្អែកឡើងនៅថ្ងៃមិនចាំ ខែ ឧសភា ឆ្នាំ ២០០៤ នាងខ្ញុំក៏ប្រាប់ម្ចាស់ផ្ទះថា អ៊ំខ្ញុំយល់សប្តិថា គេឱ្យកំណប់នៅឯខេត្តក្រចេះ ហើយនាងខ្ញុំនិយាយថា ទាល់តែអ្នកមានសំណាងទើបបាន ពេលនោះម្ចាស់ផ្ទះក៏មានជំនឿលើនាងខ្ញុំ ហើយនាងខ្ញុំទាមទារទៀន ១០គីឡូក្រាម ដើម្បីយកទៅសែននៅខេត្តក្រចេះ ពេលនោះម្ចាស់ផ្ទះបានឱ្យប្រាក់ខ្ញុំ ២០.០០០រៀលធ្វើដំណើរទៅ ពេលទៅដល់ភ្នំពេញនាងខ្ញុំក៏តែមកប្រាប់ម្ចាស់ផ្ទះថា ប្រាក់ ២០.០០០រៀល ទៅមិនដល់ខេត្តក្រចេះទេ ពេលនោះគាត់ក៏តែឱ្យកូនគាត់ប្រគល់ប្រាក់ឱ្យខ្ញុំចំនួន ១០ម៉ឺនរៀលទៀត ពេលបានប្រាក់ហើយនាងខ្ញុំក៏បានទៅដល់ខេត្តក្រចេះ ហើយយកប្រាក់នោះទៅទិញគ្រឿងអលង្ការក្លែងក្លាយមួយចំនួន ។ ហើយត្រឡប់មកវិញមកដល់ភ្នំពេញកូនរបស់ម្ចាស់ផ្ទះមកចាំទទួលនាងខ្ញុំ ដើម្បីត្រឡប់មកក្រុងព្រះសីហនុវិញ មកដល់ម៉ោងប្រហែល ២:០០ ខ្ញុំក៏យកមាសក្លែងក្លាយនោះបង្ហាញគាត់ និង កូនគាត់ ហើយនាងខ្ញុំក៏ទារប្រាក់ពីគាត់ចំនួន ៤០០ដុល្លាទៀត ដើម្បីទៅយកមាសឱ្យអស់ ក្រោយមកគាត់ក៏ឱ្យប្រាក់ខ្ញុំចំនួន ៣៥០ដុល្លា និង លុយខ្មែរ ១០ម៉ឺនរៀល ពេលនាងខ្ញុំទៅដល់ក្រចេះ ស្អែកឡើងខ្ញុំក៏ទិញមាសក្លែងក្លាយត្រឡប់មកវិញ មកដល់កំពង់ចាមម្ចាស់ផ្ទះ ក៏ចាំនាងខ្ញុំនៅទីនោះ ហើយក៏ដឹកនាងខ្ញុំមកភ្នំពេញ គាត់ក៏យកមាសក្លែងក្លាយនោះមកក្រុងព្រះសីហនុ ហើយគាត់បានឱ្យប្រាក់នាងខ្ញុំ ១៥០ដុល្លាទៀត នាងខ្ញុំក៏ត្រឡប់ទៅខេត្តក្រចេះវិញ ទៅដល់ដេកបានរយៈពេលពីរយប់ នាងខ្ញុំក៏ត្រឡប់មកក្រុងព្រះសីហនុវិញ មកដល់ផ្ទះនោះខ្ញុំនៅចាំម្ចាស់ផ្ទះ ហើយនាងខ្ញុំបានតេទៅរកគាត់ថា ខ្ញុំមកដល់ផ្ទះវិញ ហើយគាត់បានឱ្យនាងខ្ញុំនៅចាំទីនោះ លុះដល់ម៉ោង ០៥ជាងសមត្ថកិច្ចចាប់នាងខ្ញុំតែម្តង ។

-តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អ ស មានខ្លឹមសារថា កាលពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៤ វេលាម៉ោង ១១និង៣០នាទី នាងខ្ញុំបានទទួលដំណឹងថា មាននារីម្នាក់ឈ្មោះ ស ណ ដែលស្នាក់នៅផ្ទះ តា ទ នោះចេះទស្សន៍ទាយមើលត្រង់ នាងខ្ញុំក៏ឱ្យក្មេងទៅហៅនៅបេនឡានមកផ្ទះដើម្បីមើលឱ្យឃើញថា ខ្ញុំមានការជឿជាក់ខ្លះដោយនារីនោះនិយាយថា ឃើញមានកំណប់មាស ៧០០គីឡូក្រាម បើអ្នកណាមានវាសនាទើបអាចយកកំណប់នេះបានដោយធ្វើពិធីបួងទៀន ។ បន្ទាប់ពីមើលហើយខ្ញុំក៏បានឱ្យនារីនោះស្នាក់នៅមួយយប់ លុះព្រឹកឡើង

ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៤ ក៏ត្រឡប់ទៅវិញ ខ្ញុំក៏ប្រគល់ប្រាក់ចំនួន ២០.០០០រៀល ទៅសាកមើលពេលចេញទៅបាត់នៅរសៀលថ្ងៃដដែលនោះ ឈ្មោះ **ស ណា** បានទូរស័ព្ទមកនាងខ្ញុំថា គេត្រូវការទៀន ២០គីឡូបូជាទើបយកកំណប់នោះបាន ដូច្នេះ ២០.០០០រៀលធ្វើមិនបានទេ ពេលនោះខ្ញុំដោយមានការជឿជាក់ខ្លាំងពេក នាងខ្ញុំបានប្រាប់ឱ្យនារីនោះយកលុយពីកូនខ្ញុំនៅភ្នំពេញ ។ លុះដល់ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៤ នារី **ស ណា** បានទូរស័ព្ទមកថាយកកំណប់បានហើយ ពេលនោះនាងខ្ញុំប្រាប់ថា ឱ្យគេទៅទទួលនៅពោធិចិនតុងដឹកមកផ្ទះអូរមួយ វេលាម៉ោង ២:០០ រសៀល រួចនាងខ្ញុំបានប្រាក់បន្ថែមចំនួន ៣៥០ដុល្លា បន្ទាប់ពីទទួលបានកំណប់មួយចំនួនហើយ ប៉ុន្តែមិនដឹងថា កំណប់មាសនោះក្លែងក្លាយទេ ។ លុះត្រឡប់ទៅវិញនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៤ ឈ្មោះ **ស ណា** បានទូរស័ព្ទមកប្រាប់ថា យកកំណប់នោះបានទៀតហើយ រួចនាងខ្ញុំបានប្រាប់ថា នៅចាំខេត្តកំពង់ចាម ចាំខ្ញុំទៅទទួលនៅវេលាម៉ោង ១០ យប់ នាងខ្ញុំក៏បានជួបនារីនោះនៅខេត្តកំពង់ចាម និង បានទទួលមាសក្លែងក្លាយនោះបន្ថែមជាលើកទី ២ ពីនារី **ស ណា** ហើយបានជិះឡានជាមួយនាងខ្ញុំមដល់ភ្នំពេញ លុះព្រឹកឡើងថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៤ ឈ្មោះ **ស ណា** ក៏ត្រឡប់ទៅវិញ ចំណែកខ្ញុំ និង កូនពីរនាក់ទៀត បានវិលត្រឡប់មកកំពង់សោមពិនិត្យមើលមាសនោះ ទើបដឹងថាសុទ្ធតែក្លែងក្លាយទាំងអស់ ដោយអស់សង្ឃឹម នាងខ្ញុំក៏ប្រើល្បិចទំនាក់ទំនងជាមួយម្តងទៀត ។ លុះដល់ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៤ វេលាម៉ោង ១៧:០០ល្ងាច ទើបបានឃើញនារី **ស ណា** មកជួបនាងខ្ញុំនៅផ្ទះអូរទី ១ នាងខ្ញុំក៏រាយការណ៍ជូនសមត្ថកិច្ចឃាត់ខ្លួនតែម្តងទៅ ។

ចំពោះរឿងនេះនាងខ្ញុំសុំទាមទារប្រាក់ដែលបាត់បង់ដោយសារនារី **ស ណា** ឆបោកខ្ញុំវិញចំនួន ៥៥០ដុល្លា និង សូមឱ្យផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

-តាមសេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការថា ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយឱ្យការរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងមានភស្តុតាងគ្រប់គ្រាន់ ដែលអាចបញ្ជាក់បានយ៉ាងច្បាស់អំពីអំពើឆបោករបស់ឈ្មោះ **ស ណា** បានប្រើល្បិចឱ្យឈ្មោះ **ឡ ស** ជឿតាមក្នុងការស្រម័យ ហើយបានប្រគល់ប្រាក់ឱ្យខ្លួនប្រាកដមែន ។ នេះជាអំពើឆបោកមួយ ដែលមានចែងក្នុងមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ សុំតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

-តាមសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទបានទទួលកំហុស ហើយបានសារភាពចំពោះមុខតុលាការនូវរាល់អំពើរបស់ខ្លួនរួចហើយ ជនជាប់ចោទថា មនុស្សមិនចេះអក្សរត្រូវបានប្តីធ្វើបាប ជាស្ត្រីមេម៉ាយមានផ្ទៃពោះជិតគ្រប់ខែទៀតផង ។ នៅក្នុងស្ថានភាពដ៏សែនលំបាកនេះ សុំលោកតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ជនជាប់ចោទដោយក្តីអនុគ្រោះ ។

-ជនជាប់ចោទឈ្មោះ **ស ណា** បានសុំឱ្យតុលាការជួយបន្ថយទោស និង ដោះលែងខ្លួនវិញផង ពីព្រោះខ្លួនមានផ្ទៃពោះជិតគ្រប់ខែហើយ និង សុំចេញទៅសំរាលកូន ។ ខ្លួនដឹងកំហុសហើយ ឈប់ប្រព្រឹត្តអំពើឆបោកគេទៀតហើយ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយឱ្យការរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ

-ក្រោយពីបានពិនិត្យឯកសារ និង ភស្តុតាងនានា ដែលទាក់ទិនក្នុងរឿងនេះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវី

breach of Trust

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

**តុលាការខេត្តព្រះសីហនុ ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**យល់ឃើញថា**

-កាលពីថ្ងៃទី ០៩.១០ ខែ ឧសភា ឆ្នាំ ២០០៤ ពិតជាមានអំពើឆបោក ប្រព្រឹត្តនៅភូមិ ៥ សង្កាត់ ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលបណ្តាលឱ្យជនរងគ្រោះឈ្មោះ អ ស បាត់បង់ប្រាក់ប្រាកដមែន ។

-ការបាត់បង់ប្រាក់នេះដោយសារឈ្មោះ ស ណ បានប្រើល្បិចបញ្ឆោះបញ្ចុលអូសទាញឈ្មោះ អ ស ថា មានកំណប់មាស អ្នកមានវាសនាទើបអាចយកកំណប់នេះបាន ដោយជឿក្នុងការស្រមៃនេះជនរងគ្រោះបានឱ្យប្រាក់ចំនួន ៥៥០ដុល្លា គិតជាប្រាក់ខ្មែរស្មើនឹងប្រាក់ខ្មែរ ២.២០០.០០០រៀល "ពីរលានពីរសែនរៀល" ទៅជនជាប់ចោទ ដើម្បីទៅយកកំណប់មាសនោះ ។

-ក្រោយពីបានប្រាក់ហើយឈ្មោះ ស ណ មិនបានទៅយកមាសនោះទេ គឺទៅទិញមាសក្លែងក្លាយឱ្យ អ ស ដោយដឹងល្បិចកលនេះទាន់ពេល ឈ្មោះ អ ស បានទៅរាយការណ៍ជូនសមត្ថកិច្ច ទើបអាចចាប់ជននេះបានព្រមទាំងដកហូតវត្ថុតាងមាសក្លែងក្លាយជាក់ស្តែងទៀតផង ។ ជនជាប់ចោទបានឆ្លើយសារភាពថា ពិតជាមាសក្លែងក្លាយខ្លួនទិញ ដើម្បីឆបោកឈ្មោះ អ ស ប្រាកដមែន ។

-ជនជាប់ចោទឈ្មោះ ស ណ ជាសមត្ថជន ត្រូវតែទទួលខុសត្រូវនូវរាល់អំពើប្រព្រឹត្តរបស់ខ្លួន ។

-មានធាតុផ្សំបទល្មើស និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ស ណ ពីបទឆបោក ប្រព្រឹត្តកាលពីថ្ងៃទី ០៩.១០ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណី អ ស បានប្តឹងសុំទាមទារប្រាក់ ដែលបាត់បង់វិញចំនួន ៥៥០ដុល្លាអាមេរិក ស្មើនឹងប្រាក់រៀលចំនួន ២.២០០.០០០រៀល "ពីរលានពីរសែនរៀល" និង សុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

-ជនជាប់ចោទជាស្ត្រីមេម៉ាយមិនចេះអក្សរព្រមទាំងមានផ្ទៃពោះជិតគ្រប់ខែទៀត ហើយខ្លួនបានសុំឱ្យតុលាការជួយបន្ធូរបន្ថយទោស តុលាការនឹងពិចារណាដល់បញ្ហានេះក្នុងការវិនិច្ឆ័យសេចក្តី ។

**ហេតុដូច្នេះសំរេច**

១-ផ្តន្ទាទោសឈ្មោះ ស ណ ដាក់ពន្ធនាគារកំណត់មួយឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៤ ពីបទឆបោក ប្រព្រឹត្តនៅភូមិ ៥ សង្កាត់ ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៩.១០ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ឱ្យឈ្មោះ ស ណ សងសំណងជាទឹកប្រាក់ចំនួន ៥៥០ដុល្លាស្មើនឹងប្រាក់រៀល ២.២០០.០០០រៀល "ពីរលានពីរសែនរៀល" ទៅឱ្យឈ្មោះ អ ស ជាដើមបណ្តឹងរដ្ឋប្បវេណីវិញ គិតចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ ។

ក្នុងករណីគ្មានប្រាក់សងធនទណ្ឌទេ ត្រូវដាក់គុកបង្ខំដល់រូបកាយតាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមជំនុំជម្រះ |
| --- | --- |
| [redacted] | [redacted] |

April/2004 — 11/2004

F1

F1

520 US$

[redacted]